# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២១ របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (ធអ.ក) សូមជម្រាបជូនភាគហ៊ុនិក វិនិយោគិន និងសាធារណជនទទួលជ្រាបថា មហាសន្និបាតភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៤:០០នាទី ដល់ម៉ោង ១៦:០០នាទី តាមរយៈអ៊ីម៉ែល មានកូរ៉ុមចំនួន **៩៩,២១%** និងភាគហ៊ុនិកចូលរួមចំនួន **៤១៦** ស្មើនឹង **៤២៩.៧៥៣.៧៣៦** ភាគហ៊ុន។

អង្គប្រជុំបានពិនិត្យ ពិភាក្សា និងបានអនុម័តនូវចំណុចដូចខាងក្រោមៈ

១- អនុម័តកំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។**

២- អនុម័តកំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកពិសេសតាមរយៈអ៊ីម៉ែលនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៩ ភាគរយ ។**

៣- អនុម័តកំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៨ ភាគរយ។**

៤- អនុម័តគោលការណ៍ការដំឡើងកម្រៃសេវាក្រុមប្រឹក្សាភិបាល។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៤ ភាគរយ។**

៥- អនុម័តការដំឡើងកម្រៃសេវាក្រុមប្រឹក្សាភិបាលស្របនឹងអត្រាអតិផរណាប្រចាំឆ្នាំ២០២០ ចំនួន ២,៩%។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៦ ភាគរយ។**

៦- អនុម័តការបែងចែកភាគលាភ (ដែលនឹងត្រូវអនុម័តចុងក្រោយដោយនិយ័តករ) ជាសាច់ប្រាក់ចំនួន ៣០% នៃប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ ប្រចាំឆ្នាំ២០២០ (USD១៤១.៦៦២.០៣៧) ស្មើនឹង USD៤២.៤៩៣.២៩២,១៧ ក្នុងអត្រា USD០,០៩៨១ ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញសុទ្ធដែលនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

៧- អនុម័តកាលបរិច្ឆេទកំណត់ទុកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ សម្រាប់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៨ ភាគរយ។**

៨- អនុម័តគោលការណ៍ភាគលាភ។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

៩- អនុម័តគោលការណ៍លាភការ និងការតែងតាំង។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

១០- អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំ សម្រាប់ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ "A+" ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៦ ភាគរយ។**

១១- អនុម័តលើការតែងតាំងលោក Stéphane MANGIAVACCA មកពីស្ថាប័ន COFIBRED ជាអភិបាលនៅធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

១២- អនុម័តលើការតែងតាំងលោក Albertus BRUGGINK មកពីស្ថាប័ន ORIX ជាអភិបាល នៅធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

១៣- អនុម័តលើការតែងតាំងលោក Pieter KOOI ជាអភិបាលឯករាជ្យ នៅធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៧ ភាគរយ។**

១២- អនុម័តមិនបន្តអាណត្តិលោក Ian S. Lydall ជាអភិបាលឯករាជ្យ នៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងអនុម័តជ្រើសរើសអភិបាលឯករាជ្យថ្មីជំនួសលោក Ian S. Lydall។ **ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៦៩,២៩ ភាគរយ។**

ថ្ងៃសុក្រ ១២កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**